## និយមន័យ

**ការធ្វើចំណាកស្រុក:** គឺជាការផ្លាស់ទីចេញពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ដើម្បីស្វែងរកឱកាសការងារប្រសើរជាងមុន។

**ការជួញដូរមនុស្ស:** គឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ឬការទទួលមនុស្ស ដោយមធ្យោបាយនៃការគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងៗទៀតនៃការបង្ខិតបង្ខំ ការជំរិត ការបោកប្រាស់ ការល្បួងលោម ការរំលោភបំពាននៃអំនាចឬតួនាទី ដែលអាចធ្វើឲ្យបុគ្គលងាយរងគ្រោះ ឬផ្តល់ឲ្យ ឬទទួលបាននូវការទូទាត់ ឬអត្ថប្រយោជន៍ផ្សេងៗ ដើម្បីសម្រេចបាននូវការព្រមព្រៀងរបស់បុគ្គល ដោយឃុំគ្រង ឬត្រួតត្រាទៅលើបុគ្គលនោះ ក្នុងគោលបំណងនៃការកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចនឹងរាប់បញ្ចូលទាំងកំរិតអប្បបរមា នៃការកេងប្រវ័ញ្ចអំពើពេស្យាចាររបស់អ្នកដទៃ ឬទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការងារបែបបង្ខំ ឬសេវាកម្មផ្សេងៗ ទាសភាព ឬការអនុវត្តស្រដៀងគ្នាទៅនឹងទាសភាព ឬការយកចេញនៃសរីរាង្គមនុស្ស។

**ការរត់ពន្ធមនុស្ស:** គឺជាការសម្របសម្រួល ដើម្បីជួយនរណាម្នាក់ ក្នុងការឆ្លងដែនពីប្រទេសមួយទៅកាន់ប្រទេសមួយទៀតដោយខុសច្បាប់ ក្នុងគោលបំណងចង់បានផលប្រយោជន៍ហិរញ្ញវត្ថុ ឬសម្ភារៈ។

## ហេតុអ្វីអ្នកត្រូវធ្វើចំណាកស្រុក?

<u>កត្តាជំរុញ</u>

- ជីវភាពខ្វះខាត
- គ្មានការងារធ្វើ
- ប្រាក់ឈ្នួល/ចំណូលតិចក្នុងប្រទេស
- ជំពាក់បំណុលគេ
- ខ្វះដីធ្លីធ្វើស្រែចំការ
- បាត់បង់ដីធ្លី ។ល។

<u>កត្តាអូសទាញ</u>

- ប្រាក់ឈ្នួលខ្ពស់
- ចង់បានបទពិសោធន៍ និងជំនាញថ្មីៗ
- តម្រូវការកំលាំងពលកម្មនៅប្រទេសទទួល
- សម្ភារៈនិយម
- គោលនយោបាយនាំពលករចេញ

## តើអ្វីខ្លះជាលក្ខខណ្ឌតំរូវសម្រាប់ពលករស្របច្បាប់?

☞ **ចំណាកស្រុកស្របច្បាប់ត្រូវមាន៖**

- លិខិតឆ្លងដែន (ប៉ាស្ព័រ)
- ទិដ្ឋាការ (វីសារ)
- លិខិតអនុញ្ញាតការងារ
- ទទួលបានការការពារដោយច្បាប់ការងារ
- ទទួលបានសេវាសង្គម ការថែរក្សាសុខភាព និងទទួលបានការបណ្តុះបណ្តាលមុនពេលចេញដំណើរពីរដ្ឋាភិបាល ក្រុមហ៊ុន អង្គការ ឬភាគីពាក់ព័ន្ធ
- លក្ខខណ្ឌការងារសមស្រប
- ទៅតាមរយៈក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់

☞ **ចំណាកស្រុកដោយមិនស្របច្បាប់/មិនប្រក្រតី៖**

- មិនមានលិខិតឆ្លងដែន (ប៉ាស្ព័រ)
- មិនមានទិដ្ឋាការ (វីសារ)

អង្គការខារ៉ាមកម្ពុជា

# តើអ្នកបានស្វែងយល់ព័ត៌មានចំណាកស្រុកហើយឬនៅ?

**តើពលករចំណាកស្រុក ក្រុមគ្រួសារ ឬសហគមន៍របស់ពួកគេត្រូវការជំនួយអន្តរាគមន៍ ឬស្វែងយល់ពីសេវាកម្មផ្សេងៗទៀតអ្វីខ្លះ?**

☑ស្វែងរកកិច្ចអន្តរាគមន៍ដល់ពលករក្នុងករណីលក្ខខណ្ឌការងារធ្ងន់ធ្ងរ កេងប្រវ័ញ្ចកំលាំងពលកម្ម ឬការជួញដូរមនុស្ស

☑ស្វែងយល់ពីសុវត្ថិភាពចំណាកស្រុកជាមុន មុនពេលសំរេចចិត្តថាចំណាកស្រុកជាជំរើសចុងក្រោយ

☑ព័ត៌មាន/ចំងល់ ឬសេវាកម្មផ្សេងៗទៀតរបស់អង្គការ

☞ សូមមេត្តាទំនាក់ទំនងអង្គការខារ៉ាម តាមអាសយដ្ឋាន:

ផ្ទះលេខ ១៩៣AE$_0$ ផ្លូវត្រសក់ផ្អែម សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

សូមអរគុណ!

☎ **012 961 427**
☎ **012 949 914**
☎ **023 218 065**

- ប្រឈមមុខនឹងស្ថានភាពការងារបែបទាសភាព
- ប្រឈមមុខនឹងកាចាប់ខ្លួន ឃុំខ្លួន និងការបញ្ជូនត្រលប់មកប្រទេសកំណើតវិញ។

## តើអ្នកគួរត្រៀមខ្លួនដូចម្តេចខ្លះ មុននឹងចាកចេញទៅធ្វើការនៅក្រៅប្រទេស?

✍ លិខិតឆ្លងដែន (ប៉ាស្ព័រ)
✍ ទិដ្ឋាការ (វីសារ)

- លិខិតអនុញ្ញាតការងារ (ទៅតាមច្បាប់នៃប្រទេសនីមួយៗ)
- ថតចំលងទុកនូវឯកសារធ្វើតំណើរ លិខិតឆ្លង-ដែន និងអត្តសញ្ញាណប័ណ្ណរបស់អ្នកផ្ទាល់ទុកនៅក្រុមគ្រួសារ
- ទុកអាសយដ្ឋានក្រុមហ៊ុន (ឈ្មោះនិយោជក និងលេខទូរស័ព្ទ) នៅក្រុមគ្រួសារ
- យកអាសយដ្ឋាន លេខទូរស័ព្ទរបស់អង្គការ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសដែលអ្នកទៅ



*ការបណ្តុះបណ្តាល ផ្នែកច្បាប់ដល់ជនបង្គោលនៅខេត្តបន្ទាយមានជ័យ*

## សិទ្ធិរបស់ពលករមិនស្របច្បាប់/មិនប្រក្រតី នៅពេលឃុំខ្លួន ជាប់គុក ឬបញ្ជូនត្រលប់មកវិញ

ពលករមិនស្របច្បាប់/មិនប្រក្រតី អាចប្រឈមមុខនឹង ការឃុំខ្លួន ការជាប់គុក នៅប្រទេសដែលពួកគេចូលទៅធ្វើការ ឬបញ្ជូនត្រលប់ទៅកាន់ប្រទេសដើមវិញ។

ច្បាប់អន្តោប្រវេសន៍ មានភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយ ប៉ុន្តែជាទូទៅពលករចំណាកស្រុកមានសិទ្ធិនានាទាក់ទងនឹង ការឃុំខ្លួន ការជាប់គុក និងការបញ្ជូនត្រលប់ ដូចខាងក្រោមនេះ៖

- សិទ្ធិទទួលបានអ្នកបកប្រែម្នាក់ ប្រសិនបើអ្នកមិនយល់ភាសានៃប្រទេសនោះ
- សិទ្ធិទំនាក់ទំនង និងស្វែងរកជំនួយពីមន្ត្រីកុងស៊ុលនៃប្រទេសដើមកំណើតរបស់អ្នក
- សិទ្ធិបង្កើតទំនាក់ទំនងជាមួយសមាជិកគ្រួសារ និងមេធាវី
- សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃ ប្រសិនជាអ្នកមិនមានប្រាក់បង់ថ្លៃសេវា
- សិទ្ធិរក្សាភាពស្ងៀមស្ងាត់ នៅពេលឃុំខ្លួន
- អ្នកមិនត្រូវបានបំបែកចេញ ពីការថែទាំកូនរបស់អ្នក
- សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម ។ល។

## លេខទូរស័ព្ទទំនាក់ទំនង

**នៅប្រទេសកម្ពុជា**

អង្គការខារ៉ាមកម្ពុជា

: (៨៥៥-២៣) ២១៨ ០៦៥

: (៨៥៥-១២) ៩៦១ ៨២៧/៩៨៩ ៩១៤

**នៅក្រៅប្រទេស**

អង្គការខារ៉ាមម៉ាឡេស៊ី (ទីណាហ្គានីតា)

: +៦០-៣-៧៧៧០ ៣៦៧១

: +៦០-៣-៧៧៧០ ៣៦៩១

អង្គការមូលនិធិរ៉ាក់ថៃ (ប្រទេសថៃ)

: ០២-២៦៥-៦៨៨៨

: ០៩-៧១២ ៣៥៩៥ រឺ ០៣៩-៥៥៥ ២០២

: ០៧៥-៣២៦ ១១៤ រឺ ០៣៩-៥៤៤ ៤៦៤

: ០៧៧-២១៨ ៨៨៧

អង្គការ KUI SC (ប្រទេសកូរ៉េខាងត្បូង)

: +៨២-២-៧៩២-៨០

: +៨២-៣១-៤៩៥-០៥៦០

**ស្ថានទូតកម្ពុជាប្រចាំនៅក្រៅប្រទេស**

ប្រទេសម៉ាឡេស៊ី : ៦០៣-៤២៥ ៧១១ ៥០

: ៦០៣-៤២៥ ៧៥៧ ៧១

ប្រទេសកូរ៉េខាងត្បូង : (៨២២) ៣៧៨៥ ១០៤០

ប្រទេសថៃ : (០២)៩៥៧-៥៨៥១

: (០២)៩៥៧-៥៨៥២